# ព្រះពុទ្ធអង្គធំរកឃើញនៅអណ្ដូងប្រាសាទបាយ័ន

ប្រាសាទបាយ័ន មានទីតាំងស្ថិតនៅត្រង់ចំណុចកណ្ដាលរាជធានីអង្គរធំ ដែលគេស្គាល់ជាទូទៅថា ជាប្រាសាទរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨១ - ១២២០)។ ប្រាសាទនេះ មានរចនាសម្ព័ន្ធស្មុគស្មាញខ្លាំង និងចែកចេញជា ៣ ថ្នាក់សំខាន់ៗ។ ក្នុងនោះ នៅថ្នាក់ខាងលើបង្អស់ត្រង់ចំណុចប្រាង្គកណ្ដាល ដែលជាប្រាង្គមានទំហំធំ និងខ្ពស់ជាងគេ (កម្ពស់ ៤៣ម៉ែត្រពីដី) មានអណ្ដូងដ៏ជ្រៅមួយ (ជម្រៅជិត ១៤ម៉ែត្រ)។ គួរចាប់អារម្មណ៍ នៅក្នុងអណ្ដូងនេះ បុរាណវិទូជនជាតិបារាំង បានធ្វើកំណាយរកឃើញប្រតិមាព្រះពុទ្ធអង្គប្រក់នាគដ៏ធំមួយអង្គ ដែលអ្នកប្រវត្តិវិទូមួយចំនួនហៅព្រះពុទ្ធអង្គធំនេះថា "**ជ័យពុទ្ធមហានាថ**"។ តើប្រតិមាព្រះពុទ្ធអង្គធំរកឃើញនៅក្នុងអណ្ដូងប្រាសាទបាយ័ន មានប្រវត្តិ និងលក្ខណៈដូចម្ដេចខ្លះ?

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៣៣ បុរាណវិទូជនជាតិបារាំងឈ្មោះ George Trouvé បានដឹកនាំក្រុមការងារធ្វើកំណាយនៅក្នុងរណ្ដៅដ៏ជ្រៅមួយដែលរាងបួនជ្រុងស្មើ នៃប្រាង្គកណ្ដាលប្រាសាទបាយ័ន (សព្វថ្ងៃអ្នកស្រុកហៅថា "**អណ្ដូងព្រេង**") ដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅអំពីប្រវត្តិរបស់ប្រាសាទ។ ក្នុងកំណាយនោះ គេជីករហូតដល់ជម្រៅដី ១៤ ម៉ែត្រ ដែលស្មើនឹងកម្រិតដីរាបនៃប្រាសាទ។ ប៉ុន្តែ នៅពេលជីកដល់ជម្រៅដីត្រឹមតែ ៩ ម៉ែត្រប៉ុណ្ណោះ គេបានប្រទះឃើញបំណែកព្រះពុទ្ធរូបប្រក់នាគដ៏ធំមួយអង្គដែលមានកម្ពស់រហូតដល់ទៅ ៣,៦០ ម៉ែត្រ (តម្កល់នៅលើជើងទម្រមួយដែលមានរាងប្រាំបីជ្រុង) កប់លាយឡំជាមួយព្រះសិរ និងព្រះកាយព្រះពុទ្ធរូបតូចៗជាច្រើនទៀតដែលមានទម្រង់ជាសិល្បៈដើមសម័យអយុធ្យា (សៀម) នៅក្នុងអណ្ដូងជាមួយគ្នា។ អំឡុងពេលរកឃើញនោះ អ្នកស្រាវជ្រាវបានចាត់ទុកព្រះប្រតិមាអង្គនេះ ជាប្រតិមាស្នូលនៃអាណាចក្រខ្មែរនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (ចុងស.វ.ទី១២ ដល់ដើមស.វ.ទី១៣)។ លុះក្រោយមក នៅក្នុងខែតុលា ឆ្នាំ១៩៣៣ ប្រតិមាព្រះពុទ្ធប្រក់នាគដ៏ធំនេះបានផ្គុំឡើងវិញទាំងស្រុងនៅខាងមុខទីធ្លាប្រាសាទ។ មកដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៣៤ បុរាណវិទូនៃសាលាបារាំងចុងបូព៌ាប្រទេស (EFEO) បានថ្វាយព្រះប្រតិមានេះជូនដល់សម្ដេចព្រះករុណា **ស៊ីសុវត្ថិ មុនីវង្ស**។ នៅក្នុងឆ្នាំ១៩៣៥ ព្រះករុណាបានយាងទៅតម្កល់ និងធ្វើពិធីអភិសេកបដិមានេះសម្រាប់បូជាឡើង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

វិញនៅលើខឿនព្រះវិហារវត្តប្រាំពីរល្វែង ដែលស្ថិតនៅប៉ែកឦសានប្រាសាទបាយ័ន ឬនៅខាងជើងព្រលានជល់ដំរី។ ចាប់ពីពេលនោះ ព្រះប្រតិមានេះបានតម្កល់នៅទីនោះមកទល់សព្វថ្ងៃ ពោល គឺមិនបានផ្លាស់ប្ដូរទៅទីណាទៀតនោះឡើយ ហើយគ្រាន់តែប្ដូរពីពេងឈើ មកជាសំណង់បេតុងប្រក់ពីលើប៉ុណ្ណោះ។ ចាប់ពីពេលនោះមក មានសំណួរមួយដែលតែងចោទសួរអំពីព្រះប្រតិមាព្រះពុទ្ធអង្គធំនេះថា តើព្រះពុទ្ធរូបនេះ ពិតជាព្រះអាទិទេពដើមនៃប្រាង្គកណ្ដាលប្រាសាទបាយ័នមែន ឬយ៉ាងណា?

ព្រះពុទ្ធរូបអង្គនេះ មានសិល្បៈជាទម្រង់រូបតំណាងដ៏ពេញនិយមបំផុតនាសម័យអង្គរ។ ព្រះអង្គគង់ក្នុងទម្រង់ធ្យានមុទ្រា ពោល គឺការតាំងសមាធិយ៉ាងជ្រាលជ្រៅ ព្រះនេត្របិទទម្លាក់ចុះក្រោម គង់នៅលើនាគក្បាលប្រាំពីរ ហើយក្បាលនាគទាំងនោះងើបឡើងលើធ្វើជាដំបូលប្រក់ការពារព្រះអង្គ។ អ្នកប្រាជ្ញជាច្រើននៅសម័យមុន ដូចជា លោក George Coedès (ឆ្នាំ១៩២៣) និងលោក Pierre Dupont (ឆ្នាំ១៩៥០) បានបកស្រាយតាមបែបនិម្មិតរូបថា ការរចនាព្រះប្រតិមាបែបនេះ គឺជាការសំយោគចូលគ្នារវាងជំនឿដើមរបស់ខ្មែរលើការគោរពនាគ និងព្រះពុទ្ធសក្យមុនីដែលត្រូវបានការពារដោយនាគមុចលិន្ទ ក្នុងអំឡុងពេលដែលព្រះពុទ្ធត្រាស់ដឹង នៃព្រះពុទ្ធសាសនាថេរវាទ។ ប៉ុន្តែ អ្នកស្រាវជ្រាវជំនាន់ក្រោយជាច្រើនទៀតយល់ឃើញថា ព្រះប្រតិមានេះមិនជាប់ពាក់ព័នជាមួយព្រះពុទ្ធសាសនាថេរវាទនោះឡើយ ពោល គឺជាប់ពាក់ព័ន្ធទៅនឹងព្រះពុទ្ធសាសនាមហាយាន ឬវជ្រយាន។ ជាក់ស្ដែង ដូចជា លោក Peter D. Sharrock គិតថា ព្រះពុទ្ធប្រក់នាគនៅសម័យបុរាណមួយចំនួន អាចជារូបតំណាងនៃព្រះពុទ្ធអមិតាភៈ ដែលប្រតិស្ឋាននៅស្ថានសួគ៌ខាងលិចឈ្មោះថា “**សុខាវតី**”។ ក្រៅអំពីនេះ ព្រះពុទ្ធអង្គដ៏ធំនេះ ក៏ត្រូវបានគេចាត់ទុកថាជា “**ពុទ្ធរាជ**” តាមបែបព្រះពុទ្ធសាសនា ជំនួសឱ្យ “**ទេវរាជ**” នៃព្រហ្មញ្ញសាសនា (ព្រះសិវ ឬវិស្ណុ)។ ក្នុងនោះ លោក George Coedès (ឆ្នាំ១៩៤៨, ១៩៤៨) យល់ឃើញថា ព្រះពុទ្ធរូបរកឃើញនៅប្រាសាទបាយ័ន គឺជារូបនិម្មិតរូបនៃការលើកតម្កើងព្រះបាទជ័យវរ្ម័នទី៧ ឱ្យក្លាយទៅជាទេព ហើយព្រះប្រតិមានេះ គឺជាការប្រមូលផ្ដុំនូវរាល់ព្រះប្រតិមាទាំងឡាយដែលមានរៀបរាប់ព្រះនាមនៅក្នុងថែវជាន់ខាងក្រោមនៃប្រាសាទបាយ័ន។ អ្នកស្រាវជ្រាវខ្លះទៀត រួមមានដូចជា លោក Paul Mus (ឆ្នាំ១៩៦២) និងលោក Bernard Phillipe Groslier រួមជាមួយលោក Jacques Dumarçay (ឆ្នាំ១៩៧៣) បានព្យាយាមបកស្រាយព្រះពុទ្ធរូបនេះតាមបែបជំនឿខាងវិញ្ញាណនៅអង្គរ ដោយជឿ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ថា ព្រះពុទ្ធរូបរកឃើញនៅប្រាសាទបាយ័ននេះ គឺជានិម្មិតរូបនៃព្រះបាទជ័យវរ្ម័នទី៧ ក្នុងតួនាទីជា **"អ្នកតាធំ"** នៃអាណាចក្រខ្មែរ ដែលបង្ហាញអំពីអំណាចរបស់ព្រះអង្គតាមរយៈការប្រមូលផ្ដុំ "អ្នកតាម្ចាស់ទឹកម្ចាស់ដី" ឱ្យមកស្ថិតនៅក្រោមព្រះបាទ (ជើង) របស់ទ្រង់។ ទោះជាមានការបកស្រាយពីសំណាក់អ្នកស្រាវជ្រាវជាច្រើនយ៉ាងណាក៏ដោយ គ្មានសិលាចារឹកណាមួយនៅប្រាសាទបាយ័ន ឬប្រាសាទផ្សេងទៀតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដែលបានកត់ត្រាអំពីព្រះពុទ្ធរូបនេះឡើយ ហើយសូម្បីតែព្រះនាម **"ជ័យពុទ្ធមហានាថ"** ដែលមានកត់ត្រានៅក្នុងសិលាចារឹកប្រាសាទព្រះខ័ន ក៏មិនប្រាកដថាជាព្រះនាមដើមរបស់ព្រះពុទ្ធរូបរកឃើញនៅក្នុងអណ្ដូងនៃប្រាង្គកណ្ដាលប្រាសាទបាយ័ននេះឡើយ។

ការសិក្សាបែបវិទ្យាសាស្ត្រមួយថ្មីរបស់លោក Martine Polkinghorne និងសហការី (ឆ្នាំ ២០១៣) បានសន្និដ្ឋានថា ព្រះពុទ្ធអង្គធំនេះ ទំនងសង់ឡើងនៅចុងស.វ.ទី១២ (រចនាបថបាយ័ន) នៅអំឡុងពេលដែលព្រះពុទ្ធប្រក់នាគគឺជាទេពដ៏លេចធ្លោបំផុត ហើយព្រះពុទ្ធអង្គនេះបង្ហាញពីព្រះភក្ត្របែបអាថ៌កំបាំង និងស្នាមញញឹមនៃសម័យអង្គរ។ ព្រះភក្ត្រ រូបរាង អវយៈ សាច់ដុំ និងកាយវិការ គឺស្រដៀងគ្នាទៅនឹងរូបសំណាកដែលគេជឿថាជាព្រះបាទជ័យវរ្ម័នទី៧ *(រកឃើញនៅអង្គរធំ, ប្រាសាទបាកាន្ត, ប្រាសាទភិមាយ)*។ ព្រះពុទ្ធអង្គរកឃើញនៅបាយ័ន គឺបង្ហាញអំពីការសមាធិតាមរយៈព្រះនេត្រដែលបិទពាក់កណ្ដាល ពោល គឺជានិម្មិតរូបដាស់តឿនដល់វិញ្ញាណនៃសេចក្ដីមេត្តាករុណា និងជាទម្រង់លក្ខណៈពិសេសនៃសិល្បៈខ្មែររចនាបថបាយ័ន។ ចំណែក ព្រះកេសា គឺមានរូបគូទខ្យងតូចៗដែលឆ្លាក់ជាក្បាច់រាក់ៗ ស្រដៀងព្រះពុទ្ធរូបកាលពីសម័យមុនក្នុងរចនាបថបាភួន។ ព្រះកាណ៌វែង យារធ្លាក់ទៅដល់ព្រះកាយ រីឯគ្រឿងអលង្ការ និងសម្លៀកបំពាក់រចនាឡើងក្នុងទម្រង់បែបសាមញ្ញ ដោយមានស្បង់ចីវរតភ្ជាប់ពីព្រះហស្តឆ្វេងទៅព្រះកាយ។ ប្រតិមាព្រះពុទ្ធអង្គនេះ មានលក្ខណៈខុសប្លែកពីគេត្រង់ថាមានទំហំធំសម្បើម និងឆ្លាក់ពីថ្មភក់ពណ៌សដ៏ចម្លែក ដែលកាលពីដំបូងឡើយ លោក Trouvé យល់ច្រឡំថាជាថ្មក្រានីត។

ដើម្បីបកស្រាយថា តើព្រះប្រតិមានេះពិតជាមានទីតាំងនៅប្រាង្គកណ្ដាលនៃប្រាសាទបាយ័នមែនឬមិនមែននោះ លោក Martine Polkinghorne និងសហការី (ឆ្នាំ២០១៣) បានសិក្សា និងបកស្រាយតាមរយៈការផ្ទៀងផ្ទាត់ជាមួយសិលាចារឹកប្រាសាទព្រះខ័ន ដែលរៀបរាប់អំពីពិធីបុណ្យប្រចាំឆ្នាំ។ ពិធីបុណ្យនោះ គេបានរំឭកដល់ទេពសំខាន់ៗជាច្រើននៅជុំវិញអាណាចក្រខ្មែរ

ដូចជា នៅប្រាសាទវត្តនគរ ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយឆ្មារ និងប្រាសាទភិមាយ។ ប៉ុន្តែ គួរឱ្យចម្លែក គេមិនបានរៀបរាប់រំឭកដល់ព្រះពុទ្ធរូបនៅប្រាសាទបាយ័នអង្គនេះឡើយ។ ដូច្នេះ គេអាចពិចារណាថា មូលហេតុដែលគេមិនរំឭកដល់ព្រះពុទ្ធអង្គនៅប្រាសាទបាយ័នដូច្នេះ ប្រហែលមកពីសិលាចារឹកនេះចារឡើងមុនពេលអភិសេកព្រះពុទ្ធអង្គនេះ។ បន្ថែមពីនេះ តាមរយៈទំហំដ៏ធំ និងទម្ងន់ដ៏ធ្ងន់ (១៥តោន) របស់ព្រះពុទ្ធអង្គធំនេះ គឺច្បាស់ណាស់ថា ដើម្បីដំឡើងព្រះពុទ្ធអង្គនេះដាក់តម្កល់នៅក្នុងប្រាសាទបាន លុះត្រាតែមានការរៀបចំផែនការយ៉ាងហ្មត់ចត់។ ក្នុងករណីនេះ ដោយសារតែព្រះពុទ្ធអង្គនេះមានកម្ពស់ខ្ពស់ជាង និងទទឹងធំជាង ខ្លោងទ្វារនៃប្រាង្គកណ្តាលប្រាសាទបាយ័ន នាំឱ្យលោក Claude Jacques (ឆ្នាំ១៩៩៩) និងលោក Oliver Cunin (ឆ្នាំ២០០៧) យល់ឃើញថា គេបានតម្កល់ព្រះពុទ្ធរូបនេះតាំងពីមុនកសាងប្រាង្គកណ្តាលប្រាសាទបាយ័ន្តមកម្ល៉េះ ដោយសារតែគេរកឃើញថា នៅទីនោះមានរចនាសម្ព័ន្ធបណ្តោះអាសន្នចាំបាច់ដើម្បីការពារព្រះប្រតិមាអង្គនេះ។ គំនិតគួរឱ្យចាប់អារម្មណ៍មួយរបស់លោក Jacques (ឆ្នាំ២០០៧) បានគិតថា នៅពេលមានចលនាប្រឆាំងនឹងព្រះប្រតិមានៃព្រះពុទ្ធសាសនាបន្ទាប់ពីរាជ្យព្រះបាទជ័យវរ្ម័នទី៧ ប្រហែលគេបានយករូបសំណាកព្រះហរិហរមកជំនួសកន្លែងព្រះពុទ្ធអង្គនេះ ដោយយោងទៅលើសិលាចារឹកនៅក្នុងប្រាង្គជាប់ៗគ្នាមានរំឭកដល់ព្រះនាងបរ្វតី និងព្រះនាងធរណី ដែលជាមហេសីរបស់ព្រះសិវ និងព្រះវិស្ណុ។ ប៉ុន្តែ លោក Martine Polkinghorne និងសហការី (ឆ្នាំ២០១៣) ជឿថា សម្មតិកម្មនេះទំនងមិនត្រឹមត្រូវឡើយ ព្រោះយ៉ាងហោចណាស់គេបានគោរពប្រណិប័តន៍ចំពោះព្រះពុទ្ធអង្គនេះរហូតដល់ស.វ.ទី១៥។ ដោយឡែក លោក Dumarçay (ឆ្នាំ១៩៩៦) បង្ហាញទស្សនៈដ៏ត្រឹមត្រូវមួយថា ដើម្បីសែងប្រតិមាព្រះពុទ្ធអង្គនេះយកទៅតម្កល់ក្នុងប្រាង្គកណ្តាលប្រាសាទបាយ័នបាន គេត្រូវសែងផ្តៀងបណ្តោយរូប ដូចដែលពេលលោក Trouvé បានសែងយកចេញពីក្នុងរណ្តៅកំណាយដូច្នោះដែរ ហើយលោកគិតថា គេបានសង់បញ្ចប់ជាស្ថាពរ និងធ្វើពិធីបុណ្យឆ្លងព្រះពុទ្ធរូបអង្គនេះ (បើកព្រះនេត្រ) នៅពេលបញ្ចប់ការសាងសង់។ តាមរយៈការលើកឡើងដូច្នេះ លោក Martine Polkinghorne និងសហការី (ឆ្នាំ២០១៣) យល់ឃើញថា ប្រសិនបើគេសែងព្រះពុទ្ធអង្គនេះដោយការសែងផ្តៀងបណ្តោយរូប យកទៅតម្កល់ក្នុងប្រាសាទមែននោះ គឺមិនមានភស្តុតាងរឹងមាំណាមួយដែលអាចបញ្ជាក់ថា ព្រះពុទ្ធអង្គនេះ គឺជាព្រះប្រតិមាដើមរបស់ប្រាសាទបាយ័នតាំងពីដំបូងមកនោះឡើយ ព្រោះគេអាចនឹងដឹកជញ្ជូនរូបនេះចូល និងចេញតាម

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ទ្វារខាងកើត ឬខាងលិចនៃប្រាង្គកណ្ដាលពីកន្លែងណាមួយ នៅក្នុងពេលណាមួយនៅសម័យក្រោយក៏អាចថាបាន។

ចំណុចគួរកត់សម្គាល់ជាពិសេសមួយទៀតនោះ ព្រះពុទ្ធរូបនេះតម្កល់នៅលើបល្ល័ង្កដែលមានរាងប្រាំបីជ្រុង ខុសប្លែកពីព្រះពុទ្ធរូបផ្សេងទៀតនៅសម័យអង្គរដែលជាទូទៅតម្កល់លើបល្ល័ង្ករាងបួនជ្រុងស្មើ ឬបួនជ្រុងទ្រវែង។ ម្ល៉ោះហើយ លោក Martine Polkinghorne និងសហការី (ឆ្នាំ ២០១៣) យល់ឃើញថា បល្ល័ង្ករាងប្រាំបីជ្រុងដែលធ្វើអំពីថ្មភក់ជាច្រើនដុំផ្គុំចូលគ្នានេះ គឺធ្វើឡើងនៅសម័យក្រោយ រវាងស.វ.ទី១៥។ ប្រសិនបើពិនិត្យពីផ្នែកខាងក្រោមមកខាងលើ បល្ល័ង្កព្រះពុទ្ធអង្គនេះមានថ្មភក់ចំនួន ៦ ជាន់ គឺរាងប្រាំបីជ្រុងចំនួន៤ជាន់ និងរាងមូលចំនួន២ជាន់។ ជាន់ប្រាំបីជ្រុងនីមួយៗមានថ្មចំនួន ៨ ដុំ ហើយដុំនីមួយៗត្រូវបានកែច្នៃឡើងវិញ ដើម្បីឱ្យត្រូវគ្នាជាមួយនឹងដុំថ្មផ្សេងទៀត ដែលដុំថ្មទាំងនោះរៀបចំឡើងឱ្យផ្ទៃម្ខាងមានទំហំប្រហែល ៤/៥ និងផ្ទៃម្ខាងទៀតមានទំហំ ១/៥។ បើពិនិត្យមើលរូបរាងបល្ល័ង្ករាងប្រាំបីជ្រុងនេះ គឺមានលក្ខណៈស្រដៀងស្តូបគោកធ្លក (ខាងលិចបាយ័ន) និងវត្តព្រះងោក (ប៉ែកពាយព្យបាយ័ន)។ កាលបរិច្ឆេទស្តូបទាំងនេះមិនសូវច្បាស់លាស់នោះទេ តែទំនងស្ថិតនៅស.វ.ទី១៥ ឬក្រោយបន្តិច ដែលស្របទៅនឹងខឿនព្រះពុទ្ធសាសនាថេរវាទដទៃទៀតនៅអង្គរ។ ម្ល៉ោះហើយ បល្ល័ង្ករាងប្រាំបីជ្រុងដែលយកមកពិចារណានេះអាចត្រូវបានគេកែប្រែម្ដងទៀត មុននឹងបោះចូលអណ្ដូងព្រេង នៅរវាងស.វ.ទី១៥ ឬ១៦។ ម្ល៉ោះហើយ ទ្រឹស្ដីចាស់ៗដែលជឿថា បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី៧សោយទិវង្គត ពួកប្រតិកិរិយាព្រហ្មញ្ញសាសនា (សិវនិយម) បានវាយកម្ទេចព្រះពុទ្ធរូបអង្គធំនេះជាបំណែកតូចៗ ហើយបោះចូលទៅក្នុងអណ្ដូងព្រេងដើម្បីលុបបំបាត់ដានព្រះពុទ្ធសាសនាមហាយាននោះ គឺហាក់ដូចជានៅមានភាពមន្ទិលនៅឡើយ។ ដ្បិត បើយោងទៅលើបល្ល័ង្ករាងប្រាំបីជ្រុងដូចបានរៀបរាប់ខាងលើ និងកស្តុតាងនៃការរកឃើញព្រះសិរព្រះពុទ្ធរូបតូចៗរចនាបថអយុធ្យាប្រមាណ ៤០ អង្គ (អំឡុងពេលដែលអយុធ្យាកាន់កាប់អង្គរនៅស.វ.ទី១៥) នៅក្នុងរណ្ដៅជាមួយព្រះពុទ្ធរូបអង្គធំនេះ គឺគេអាចសន្និដ្ឋានថា ព្រះពុទ្ធអង្គធំដែលរកឃើញនៅប្រាសាទបាយ័ននេះ មិនត្រូវបានគេបំផ្លាញចោលនៅក្នុងស.វ.ទី១៣នោះទេ។ ផ្ទុយទៅវិញ មនុស្សខ្មែរបានបន្តគោរពប្រណិប័តន៍ព្រះពុទ្ធអង្គនេះយ៉ាងខ្ជាប់ខ្ជួនរហូតដល់រវាងស.វ.ទី១៥ ឬ១៦ ហើយការដែលប្រតិមានេះត្រូវបានគេវាយបំបែកបោះចូលក្នុងអណ្ដូងព្រេងនោះ លោក Martine Polkinghorne និងសហការី (ឆ្នាំ២០១៣) សន្និដ្ឋានថា

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

អាចកើតឡើងដោយសារក្រុមចោរជីកកកាយរកវត្ថុស័ក្តិសិទ្ធិនៅរវាងស.វ.ទី១៨។ បន្ថែមអំពីនេះ ព្រះប្រតិមាព្រះពុទ្ធអង្គធំនេះ ត្រូវបានគេជួសជុលឡើងវិញនៅស.វ.ទី១៦ (សម័យលង្វែក) ដែលស្របទៅនឹងការជួសជុលប្រាសាទ ឬពុទ្ធប្រតិមាផ្សេងៗទៀតនៅប្រាសាទអង្គរវត្ត និងប្រាសាទភ្នំបាខែងដែរ។ ប្រសិនបើប្រតិមានេះ ធ្លាប់មានគេវាយកម្ទេចនិងកប់ចោលតាំងពីស.វ.ទី១៣មែននោះ ម្ល៉េះនៅស.វ.ទី១៦ គេមិនអាចរកបំណែកមកជួសជុលព្រះពុទ្ធអង្គនេះឡើងវិញបានឡើយ។ ការជួសជុលឡើងវិញនៅស.វ.ទី១៦នេះ បញ្ជាក់ឱ្យឃើញថា ទោះបីជាអាណាចក្រខ្មែរផ្លាស់ប្តូររាជធានីអង្គរក៏ដោយ ក៏ពុទ្ធប្រតិមានៅប្រាសាទបាយ័ននេះ នៅតែមានសារៈសំខាន់សម្រាប់ពុទ្ធសាសនិកដដែល។ ម្យ៉ាងវិញទៀត បើទោះបីជាដើមឡើយព្រះប្រតិមានេះ ជាព្រះពុទ្ធអង្គនៅក្នុងព្រះពុទ្ធសាសនាមហាយានក៏ដោយ ប៉ុន្តែ នៅតែបន្តដើរតួនាទីជា "ព្រះពុទ្ធស្ទូល" សម្រាប់ពុទ្ធសាសនិកនិកាយថេរវាទនៅសម័យក្រោយអង្គរដដែល។

សរុបជារួមមក ព្រះពុទ្ធអង្គធំប្រក់នាគ ឬ «ជ័យពុទ្ធមហានាថ» ដែលរកឃើញក្នុងអណ្តូងប្រាសាទបាយ័នកាលពីឆ្នាំ១៩៣៣ គឺជាប្រតិមាស្ទូលដ៏វិសេសវិសាលនៃសម័យអង្គរ។ ទោះបីជាមានទស្សនៈជាច្រើនជុំវិញអត្ថន័យនិម្មិតរូប និងប្រវត្តិកសាងក្តី ការសិក្សាថ្មីៗបានបង្ហាញថា ព្រះពុទ្ធរូបនេះ មិនធ្លាប់មានគេបំផ្លាញចោលនៅក្នុងស.វ.ទី១៣ ដោយសារជម្លោះសាសនាឡើយ។ ផ្ទុយទៅវិញ ប្រជាជនខ្មែរបានបន្តគោរពបូជាយ៉ាងខ្ជាប់ខ្ជួនរហូតដល់ស.វ.ទី១៥-១៦ ហើយថែមទាំងទទួលបានការជួសជុលឡើងវិញក្នុងសម័យលង្វែកទៀតផង។ ចំណែកការបែកបាក់ធ្លាក់ចូលអណ្តូងព្រេង អ្នកស្រាវជ្រាវបានសន្និដ្ឋានទំនងជាបណ្តាលមកពីក្រុមចោរជីកកកាយក្នុងស.វ.ទី១៨។ បច្ចុប្បន្ន ព្រះប្រតិមាដ៏ធំនេះត្រូវបានតម្កល់នៅខឿនព្រះវិហារវត្តប្រាំពីរល្វែង ដោយនៅតែបន្តតួនាទីជា «ព្រះពុទ្ធស្ទូល» ដ៏ស័ក្តិសិទ្ធិសម្រាប់ពុទ្ធសាសនិកថេរវាទតាំងពីសម័យក្រោយអង្គររហូតមកដល់សព្វថ្ងៃ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## បញ្ជីឯកសារពិគ្រោះ


អ៊ឹម សុខរិទ្ធី "ជ័យពុទ្ធមហានាថ", អត្ថបទចុះផ្សាយនៅក្នុង *យសោធរ*, តាមរយៈតំណភ្ជាប់ http://www.yosothor.org/publications/khmer-renaissance/chapter-four/chey-puth-moha-neath.html

Cœdès, G. 1934 'La destination du Bayon', *Bulletin de l'École française d'Extrême-Orient (BEFEO)*, 34, pp. 445–451.

Cœdès, G. 1943. *Pour mieux comprendre Angkor*. Imprimerie d'Extrême-Orient, Hanoi.

Cœdès, G. 1944. *Histoire ancienne des États hindouisés d'Extrême-Orient*. Hanoi: Imprimerie d'Extrême-Orient.

Dumarçay, J. 1973 *Le Bayon: Histoire architecturale du temple*. Paris: EFEO.

Polkinghorne, M., Pottier, C. and Fischer, C. 2013 'One Buddha Can Hide Another', *Journal Asiatique*, 301(2), pp. 575–624.

Sharrock, P.D., 2007 The mystery of the face towers. In: *J. Clark, ed. Bayon: New Perspectives.* Bangkok: River Books, pp. 230-81.

Trouvé, G. 1933 'Compte rendu, séance du 25 août 1933', *Journal Asiatique*, 223, pp. 24–25.

Woodward, H. (1981) Tantric Buddhism at Angkor Thom. *Ars Orientalis*, 12, pp. 57-67.


អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ ប្រតិមាព្រះអង្គធំ រកឃើញនៅប្រាសាទបាយ័ន រូបថតឆ្នាំ ១៩៣៣

(ប្រភព៖ EFEO Collection)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៖ ប្រតិមាព្រះអង្គធំ រកឃើញនៅប្រាសាទបាយ័ន រូបថតឆ្នាំ ១៩៣៣

(ប្រភព៖ EFEO Collection)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៣៖ ប្រតិមាព្រះអង្គធំ រកឃើញនៅប្រាសាទបាយ័ន រូបថតឆ្នាំ ១៩៣៣*

(ប្រភព៖ EFEO Collection)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៤៖ ប្រតិមាព្រះអង្គធំ រកឃើញនៅប្រាសាទបាយ័ន រូបថតឆ្នាំ ១៩៣៣

(ប្រភព៖ EFEO Collection)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៥៖ ប្រតិមាព្រះអង្គធំ រកឃើញនៅប្រាសាទបាយ័ន ទិដ្ឋភាពបច្ចុប្បន្ន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៦៖ ប្រតិមាព្រះអង្គធំ រកឃើញនៅប្រាសាទបាយ័ន ទិដ្ឋភាពបច្ចុប្បន្ន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី